ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការក្រុងភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៩៧៩

ចុះថ្ងៃទី២៦.១១.៩៧

សំណុំរឿងជំនុំជំរះលេខ២០៣ ។ ចុះថ្ងៃទី ២៨.០៥.៩៨

សាលក្រមលេខ១៣"ច"

ចុះថ្ងៃទី ២៣.០៦.៩៨

# តាមនាមប្រជារាស្ត្រខ្មែរ

# តុលាការក្រុងភ្នំពេញ

-បានបង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣

-បានបើកសវនាការជាសាធារណៈ នៅតុលាការក្រុងភ្នំពេញ នាថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅ :

<u>ចៅក្រមជំនុំជំរះ</u>

-លោក គ ត ចៅក្រមតុលាការក្រុងភ្នំពេញ

<u>តំណាងអយ្យការ</u>

-លោក ខ សរ ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

<u>ក្រឡាបញ្ជីសវនាការ</u>

-អ្នកស្រី ទ ចប ក្រឡាបញ្ជីតុលាការក្រុងភ្នំពេញ

ដើម្បីជំនុំជំរះលើឈ្មោះ :

១-ឈ្មោះ ចា សរ ហៅ " ថ ស " ភេទ ប្រុស អាយុ ៥២ ឆ្នាំ ជាតិ ខ្មែរ សញ្ជាតិ កម្ពុជា សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ : ផ្ទះលេខ ៤០០ ផ្លូវ ព្រះសីហនុ ក្រុម ០១ សង្កាត់ ទួលស្វាយព្រៃទី២ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ របររកស៊ី នាំបារីទៅលក់នៅប្រទេសវៀតណាម ប្រពន្ធឈ្មោះ ខ គរអ មានកូន ០៣ នាក់ ឪពុកឈ្មោះ ត ស " " ម្តាយឈ្មោះ ន ល " " ទោសពីមុនគ្មាន (គេចខ្លួន)។

២-ឈ្មោះ ៩ សច ហៅ " ម សណ " ភេទ ប្រុស អាយុ ៣១ ឆ្នាំ ជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កើតនៅ ជប់ក្រៅ ឃុំ ជប់ ស្រុក ត្បូងឃ្មុំ ខេត្ត កំពង់ចាម ។ កំរិតវប្បធម៌ "គ្មាន" សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ក្រុម១៥ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ ។ របររកស៊ី នគរបាលតម្រួតការពារ ។ ប្រពន្ធឈ្មោះ ចា សអ មានកូន ០២ នាក់ ឪពុកឈ្មោះ ម ន "រ" ម្តាយឈ្មោះ ស ន "រ" ទោសពីមុនគ្មាន ។



Scanned with CamScanner

ត្រូវចោទពីបទ "សមគំនិតក្នុងបទល្មើសធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង ត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៩ និង ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-ឈ្មោះ ម មធ ភេទ ប្រុស អាយុ ៣៤ ឆ្នាំ ជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កើតនៅភូមិ កណ្តាល ឃុំ រកាប្រាំ ស្រុក ត្បូងឃ្មុំ ខេត្ត កំពង់ចាម គំរិតវប្បធម៌ "គ្មាន" សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ផ្ទះសង់ថ្មី សង្កាត់ ផ្សារដើមគរ ខ័ណ្ឌ ទួលគោក ក្រុង ភ្នំពេញ របររកស៊ី ធ្វើទាហាន ។ ប្រពន្ធឈ្មោះ ទ ឌ មានកូន ០១ នាក់ ឪពុកឈ្មោះ ម ចា "ស" ម្តាយឈ្មោះ អ ឃ "រ" ធ្លាប់ជាប់ពន្ធនាគារ ០៣ ឆ្នាំ ។

៤-និងឈ្មោះ រ ស ហៅ "៩" ភេទ ប្រុស អាយុ ៣០ ឆ្នាំ ជាតិ ខ្មែរ សញ្ជាតិ កម្ពុជា សាសនា ព្រះពុទ្ធ របររកស៊ី កងរាជអាវុធហត្ថខេត្តរតនគិរី ។ ទីលំនៅសព្វថ្ងៃភូមិ សន្សំកុសល សង្កាត់ បឹងទំពុន ខ័ណ្ឌ មានជ័យ ក្រុង ភ្នំពេញ ។

Murder

ត្រូវចោទពីបទ "ធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដោយមានមេធាវីឈ្មោះ កញ្ញា ឆ ឌល មកពីសមាគម អិល អា-សេ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស មឡ ភេទ ស្រី អាយុ ៤០ ឆ្នាំ ជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កើតនៅភូមិ ព្រែកដាច់ ឃុំ ព្រែកដាច់ ស្រុក លើកដែក ខេត្ត កណ្តាល សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៤៤ ផ្លូវ មុនីរ៉េត សង្កាត់ ស្ទឹងមានជ័យ ខ័ណ្ឌ មានជ័យ ក្រុង ភ្នំពេញ ឪពុកឈ្មោះ ស ធឡ "ស" ម្តាយឈ្មោះ អ ឌ "រ" ប្តីឈ្មោះ ម ម "ស" មានកូន ០៧ នាក់ ។ ដោយមានមេធាវីឈ្មោះ ៩ ចធ មកពីនាយកដ្ឋានការពារអ្នកក្រីក្រ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១៦៩២ ក.ព្រ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់ចៅក្រមស៊ើបអង្កេតនៅតុលាការក្រុងភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ ម មធ បានឆ្លើយថា : ខ្លួនពុំស្គាល់ឈ្មោះ ចា សរ ហៅ "ទ ឃ" ឈ្មោះ គ ទធ និងឈ្មោះ ៩ សឃ ឡើយ ។ ឯឈ្មោះ ម ម ជាជនរងគ្រោះក៏ខ្លួនពុំស្គាល់ដែរ ។ នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ខ្លួននៅផ្ទះជាមួយប្រពន្ធ និង ម្តាយខ្លួន ហើយចំពោះចម្លើយនៅនគរបាលខ្លួនសុំបដិសេធ ឯចម្លើយនៅតុលាការក៏ខ្លួនបដិសេធ បានជាខ្លួនឆ្លើយដូច្នេះ ពីព្រោះព្រហ្មទណ្ឌ បង្ខំអោយខ្លួនឆ្លើយ ។

-ក្រឡាបញ្ជីអានកំណត់ហេតុចម្លើយរបស់ឈ្មោះ ម មធ នៅចៅក្រមស៊ើបសួរ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ បញ្ជាក់ថា ខ្លួនអាចឆ្លើយការពារខ្លួនដោយខ្លួនឯងបាន ខ្លួនមិនចាំថ្ងៃ ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ខ្លួនចេញចូលផ្ទះ អ ហៅ "៩" ធ្វើប៉េអឹម ក៏បានជួបឈ្មោះ ៩ នៅទីនោះ ។ ពេលនោះ



Scanned with CamScanner

ឈ្មោះ ៩ បានអោយខ្លួនជូនទៅផ្ទះពូកម៉ាកវានៅក្បែរសាលាបាក់ទូក ពេលនោះខ្លួនក៏ព្រមទៅ ពេលដែលខ្លួនជូនវាមកនោះវាពុំមាននិយាយអ្វីទេ ពេលមកដល់ហើយវាថាចាំស្អែកម៉ោង ០១ ទៅជួបនៅផ្ទះវា ។ ខ្លួនក៏ទៅតាមការណាត់ ហើយវាអោយខ្លួនជូនទៅស្ទឹងមានជ័យ ។ ពេលទៅដល់អង្គុយផឹកកាហ្វេ ដោយចាំយូរពេក ខ្លួនក៏ទារមកផ្ទះវិញ អា "៩" ថាកុំអាលសិន រួចវាក៏ថាទៅ ហើយអោយខ្លួនបើកក្រោយឡានពុំស្គាល់ម៉ាក ពុំចាំផ្លាកលេខ តែម ពណ៌ស បើកតាមមកដល់ពេទ្យ ឃើញឡាននោះឈប់ ហើយអា "៩" ក៏អោយខ្លួនឈប់ ពេលនោះ អា "៩" ក៏ចុះដើរសំដៅរកអ្នកបើកឡាននោះ ហើយឮសូរផ្ទុះអាវុធ ០៣ គ្រាប់ ហើយឃើញអា "៩" រត់សំដៅម៉ូតូខ្លួន ដោយដៃកាន់កាំភ្លើង ហើយបង្ខំអោយខ្លួនបើកម៉ូតូរត់អោយលឿន ។ ខ្លួនក៏ឌុបវាសំដៅទៅផ្ទះវាដាក់វាហើយ ក៏ជិះម៉ូតូទៅផ្ទះខ្លួនវិញ ។ ម៉ូតូដែលខ្លួនជិះឌុបអា "៩" គឺជាម៉ូតូខ្លួនម៉ាកស៊ុយហ្ស៊ុយគីគ្រីសស្គាល់ ពណ៌ក្រហមតែខ្លួនបិទជ័រពណ៌ត្រួយចេកបន្ថែមទៀត ។ ពេលធ្វើសកម្មភាព គឺម៉ោងប្រហែល ៣ នៅមុខពេទ្យវិសាលសុខ ។ មុនពេលធ្វើសកម្មភាពនេះឈ្មោះ ៩ ពុំដែលនិយាយប្រាប់ខ្លួនមុនទេ ថ្ងៃធ្វើសកម្មភាពគឺថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។ លុះស្អែកឡើងពេលព្រឹកខ្លួនទៅផ្ទះ អា "៩" ហើយវាអោយខ្លួនជូនវាទៅអូឡាំពិក ផ្ទះលេខ ៤០ ។ ពេលទៅដល់វាអោយខ្លួនចាំខាងក្រៅ ចំណែកវាចូលទៅក្នុងជួបអ្នកណាខ្លួនពុំដឹងទេ ។ ពេលរង់ចាំនោះឈ្មោះ ណា មកសួរខ្លួនថា ឌុបអា "៩" មករឺ ? ខ្លួនក៏ឆ្លើយថាបាទ ហើយឈ្មោះ ណា បាននិយាយតទៅទៀតថា អា "៩" ទទួលលុយពីអ្នកណា ? ខ្លួនឆ្លើយថាពុំដឹងអ្នកណាយកលុយទៅអោយអា " ៩ " ទេ ។ អា "៩" អោយលុយខ្លួនចំនួន ៧០០ ដុល្លា ( ប្រាំពីររយ ដុល្លាអាមេរិកគត់ ) ។ កាំភ្លើងដែល អា "៩" បាញ់ម៉ាក កា៥៩ ហើយកាំភ្លើងនោះនៅអា "៩" ។ លុះដល់ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ សមត្ថកិច្ចចាប់ខ្លួន ។ ក្នុងចំណោមអ្នកចាប់មកនេះក្រៅពីឈ្មោះ ៩ ខ្លួនពុំស្គាល់ទេ ខ្លួនពុំដែលជួបឈ្មោះ ណា ទេ ឈ្មោះ ៩ ពុំដែលនិយាយប្រាប់ខ្លួនថាមានគេជួលអោយសម្លាប់មនុស្សទេ ពីមុនពេលធ្វើសកម្មភាពនោះ ។

-ជនជាប់ចោទឈ្មោះ ម មឆ ក្នុងពេលសវនាការ បានឆ្លើយបញ្ជាក់ថា នគរបាលចាប់ខ្លួននៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ នៅពេលខ្លួនចេញពីធ្វើការដោយជិះម៉ូតូម៉ាកគ្រីសស្គាល់ ម៉ូតូនេះដកហូតបាត់ហើយ ។ ឯឈ្មោះ ៩ ខ្លួនស្គាល់ ព្រោះធ្វើយោធាជាមួយគ្នា ហើយខ្លួនក៏ពុំបានជួបអ្នកណានៅក្បែរសាលាបាក់ទូកទេ ព្រោះខ្លួនគ្មានស្គាល់អ្នកណាទេ ។

-ជនជាប់ចោទឈ្មោះ ៩ សច ហៅ "ណា" បានឆ្លើយថា : ឈ្មោះ ៩ និង ឆ ខ្លួនពុំស្គាល់ទេ ហើយខ្លួនសូមបដិសេធចម្លើយនៅអយ្យការ និង តុលាការក្រុងភ្នំពេញ ព្រោះនគរបាលបង្ខំខ្លួនតាំងពីដើមមក ព្រមទាំងធ្វើទារុណកម្មទៀត ។

-ក្រឡាបញ្ជីអានកំណត់ហេតុយកចម្លើយរបស់ជនជាប់ចោទឈ្មោះ ៩ សច ហៅ " ណា" នៅក្រុមស៊ើបសួរ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ បញ្ជាក់ថា : ឈ្មោះ ៩ សឃ ហៅ "ញ" ខ្លួនស្គាល់ដោយសារផ្ទះវានៅជិតផ្ទះខ្លួន ឈ្មោះ ៩ សឃ ហៅ "ញ" វាពុំដឹងអ្វីទេ ឯ ឈ្មោះ

ម មឆ ក៏ខ្លួនពុំស្គាល់ដែរ ខ្លួនធ្វើអង្គរក្សអោយឈ្មោះ ថ ស បាន ០២ ខែ ក្នុងការមកធ្វើជាអង្គរក្សនេះ ដោយសារចៅហ្វាយនាយចាត់តាំងអោយមក ហើយខ្លួនមកធ្វើអង្គរក្សអោយ ថ ស នៅខែ ០៧ ក្នុងការធ្វើអង្គរក្សនេះខ្លួនពុំដឹងថា ថ ស មានទំនាស់ជាមួយឈ្មោះ ម ម ទេ ខ្លួនពុំដឹងថាឈ្មោះ ថ ស នេះឃ្លាំងស្តាប់កូនប្រសារគាត់ទេ ។ គេចាប់ខ្លួនពេលខ្លួនកំពុងជិះម៉ូតូ គឺជិះតែម្នាក់ឯង ម៉ូតូខ្លួនម៉ាកសាន់យ៉ាន់ ឯម៉ូតូរបស់ឈ្មោះ ម មឆ ខ្លួនពុំស្គាល់ម៉ាកទេ អ្នកដែលទាក់ទិនក្នុងរឿងនេះ ខ្លួនពុំដែលស្គាល់ទេ គឺស្គាល់តែឈ្មោះ ញ ម្នាក់ប៉ុណ្ណោះ ។ មុនចាប់ខ្លួនមួយថ្ងៃ ខ្លួនបានឈ្មោះជាមួយ ឈ្មោះ ញ មែន ដោយសារឈ្មោះ ញ យកម៉ូតូខ្លួនទៅបញ្ចាំលើសតម្លៃដែលខ្លួនអោយបញ្ចាំ ដោយសារខឹងនឹងវាក៏ចេះតែឆ្លើយដាក់វាទៅ តែតាមការពិតឈ្មោះ ញ វាពុំដឹងអ្វីទេ ។

-សាក្សីឈ្មោះ អ ស បានឆ្លើយថា : ជនជាប់ចោទទាំងពីរនាក់នេះ គឺខ្លួនស្គាល់តែម្នាក់ទេ គឺឈ្មោះ ថ សច ហៅ "ណន" ព្រោះត្រូវជាប្អូនថ្លៃ ។ ឈ្មោះ ណន បាននិយាយប្រាប់ខ្លួនថា រកអ្នកសម្លាប់ឈ្មោះ ម ម តែរកពុំបានទេ ។ ខ្លួនជាមួយឈ្មោះ ណន ធ្លាប់រកឃាតករអោយសម្លាប់ ម ម ម្តងដែរ ហើយឈ្មោះ ណន បានអោយលុយខ្លួនស៊ីផឹកអស់ ១០០ ០០០ រៀល (ដប់ម៉ឺន រៀលគត់) ។ ឈ្មោះ ណន ជាអ្នកអោយលុយខ្លួនរកឃាតករ តែខ្លួនពុំបានស៊ើបរកទេ ក៏យកលុយនោះទៅលេងផ្ទះបងប្អូនចាយអស់ទៅ ។ ហើយឈ្មោះ ណន បានទៅហៅខ្លួនដល់ផ្ទះ ថាទៅរកស៊ីទិញលក់ពារី ហើយនិយាយប្រាប់ខ្លួនថា ឈ្មោះ ម ម រកស៊ីកាច់ក្នុងជាមួយឈ្មោះ ថ ស ហើយបើរកស៊ីបានអោយខ្លួនជួយរកឃាតករសម្លាប់ ម ម ឯឈ្មោះ ឌ ខ្លួនពុំស្គាល់ទេ គឺស្គាល់តែឈ្មោះ ញ ហើយឈ្មោះ អ ច ជាអ្នកហៅខ្លួនអោយធ្វើសាក្សី ខ្លួនជាសាក្សីអោយជនរងគ្រោះ ។

-សាក្សីឈ្មោះ អ ច បានឆ្លើយថា : ឈ្មោះ ណន ខ្លួនស្គាល់ច្បាស់ណាស់ ហើយឈ្មោះ អ ស ត្រូវជាប្អូនរបស់ខ្លួន ។ ឈ្មោះ ណន ត្រូវជាប្អូនជីដូនមួយរបស់ប្រពន្ធ អ ស ។ ថ្ងៃបុណ្យសពរបស់ឈ្មោះ ម ម ខ្លួនបានចូលរួមបុណ្យសពជាមួយប្អូនខ្លួនឈ្មោះ អ ស ហើយប្អូនខ្លួនមានទឹកមុខស្លេកស្លាំង ខ្លួនក៏សួរថា ហ្អែងដឹងរឿងអី វាក៏និយាយប្រាប់ខ្លួនថា ឈ្មោះ ណន បានឱ្យលុយវា ១០០ ០០០ រៀល (ដប់ម៉ឺន រៀលគត់) ដើម្បីជួយរកឃាតករ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស មឡ ជាប្រពន្ធជនរងគ្រោះឈ្មោះ ម ម បានឆ្លើយថា : ខ្លួនពុំដឹងថាប្តីខ្លួនមានទំនាស់ជាមួយឈ្មោះ ថ ស ទេ ប៉ុន្តែថ្ងៃមួយឈ្មោះ ថ ស បានទូរស័ព្ទមកប្តីខ្លួនថា អា "ម" ឯងឈប់រកស៊ីពារីទៅ បើឯងមិនឈប់ទេ អញរកគេសម្លាប់ឯងហើយ ពេលនោះប្តីខ្លួនទទួលទូរស័ព្ទហើយតបវិញថា ឯងកុំគំរាមពាល់អញ អញពុំឈប់ទេ ។ ខ្លួនពុំដឹងថាឃ្លាំងពារីរបស់ ថ ស នេះទេ ។ ខ្លួនសុំទាមទារប្រាក់ជម្ងឺចិត្ត ២០០ ០០០ ដុល្លា (ម្ភៃម៉ឺន ដុល្លាអាមេរិកគត់) និងបុណ្យសពចំនួន ១២ ម៉ឺនដុល្លា (ដប់ពីរម៉ឺន ដុល្លាអាមេរិកគត់) ។ ឈ្មោះ អ ច បានមកសុំប្តីខ្លួនធ្វើបងធម៌ប្រហែលតែមួយខែទេ ។

-ក្រឡាបញ្ជីអានកំណត់ហេតុយកចម្លើយរបស់ឈ្មោះ ត ទធ និងឈ្មោះ ជ សឃ ។ កំណត់ហេតុយកចម្លើយរបស់ឈ្មោះ ត ទធ នៅចៅក្រមស៊ើបសួរ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ បញ្ជាក់ថា : ឈ្មោះ ម ម ខ្លួនពុំដែលស្គាល់ទេ ។ ឈ្មោះ ជ ខ្លួនស្គាល់ ដោយសារធ្វើប៉េអឹមជាមួយគ្នា ហើយខ្លួនពុំដែលជូន ឈ្មោះ ជ ទៅផ្ទះថៅកែ ជ ស ទេ ។ ឈ្មោះ ជ បានហៅខ្លួនអោយជូនទៅផ្ទះពូកម៉ាកមួយភ្លែតនៅម្តុំសំណង់អនាធិបតេយ្យប៊ូលឌីញមាត់ទន្លេ ។ ខ្លួនពុំដឹងថាឈ្មោះ ជ ទៅនេះជួបអ្នកណាទេ ព្រោះខ្លួនអង្គុយចាំលើម៉ូតូខាងក្រៅមួយសន្ទុះ ក្រោយមកវាចេញមកវិញ ពេលខ្លួនដឹកវា វាពុំបាននិយាយប្រាប់ខ្លួនពីរឿងអ្វីទេ ។ ឈ្មោះ ជ ពុំដែលនិយាយប្រាប់ខ្លួនថា គេជួលអោយទៅសម្លាប់មនុស្សទេ ។ ខ្លួនពុំដឹងថាឈ្មោះ ម ម ស្លាប់ទេ ខ្លួនពុំដឹង ថា អា "ជ" ទៅសម្លាប់ទេ ។ ខ្លួនពុំដឹងថាអា "ជ" មានកាំភ្លើងទេ ។ ខ្លួនពុំដឹងថា អា "ជ" បានទទួលលុយពីគេទេ ។ ខ្លួនពុំស្គាល់ឈ្មោះ ណា ទេ ហើយខ្លួនពុំបានដឹងរឿងអ្វីទេក្នុងការសម្លាប់មនុស្សនេះ ។

-កំណត់ហេតុយកចម្លើយឈ្មោះ ជ សឃ នៅចៅក្រមស៊ើបសួរ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ បញ្ជាក់ថា : ឈ្មោះ ណា ខ្លួនស្គាល់ដោយសារផ្ទះនៅជិតគ្នា ហើយឈ្មោះ ណា ពុំដែលមករកខ្លួនអោយរកអ្នកស៊ីឈ្នួលសម្លាប់មនុស្សទេ ។ ឈ្មោះ ណា បានប្រាប់ខ្លួនអោយជួយមើលផ្ទះអោយផង ព្រោះឧស្សាហ៍បាត់ស្បែកជើង និង ខោអាវ ។ ឈ្មោះ ត ទធ ខ្លួនពុំដែលស្គាល់ទេ ។ ឯឈ្មោះ ម មធ ក៏ខ្លួនពុំដែលស្គាល់ដែរ ។ ឈ្មោះ ជ ក៏ខ្លួនពុំស្គាល់ ។ ឈ្មោះ ត និង អា "ស" ក៏ខ្លួនពុំស្គាល់ដែរ ។ ខ្លួនពុំដឹងថា ឈ្មោះ ណា ទៅរកអ្នកស៊ីឈ្នួលសម្លាប់មនុស្សឯណាទៀតទេ ។ ឈ្មោះ ម ម ក៏ខ្លួនពុំស្គាល់ដែរ ។ ផ្ទះឈ្មោះ ម ម ក៏ខ្លួនពុំស្គាល់ដែរ ។ ខ្លួនពុំដែលជូនអ្នកណាទៅស្គាល់ផ្ទះ ម ម ទេ ។ ឈ្មោះ ណា វាអន់ចិត្តនឹងខ្លួន ដោយសារវាអោយយកម៉ូតូទៅបញ្ចាំ ២០០ ដុល្លា ( ពីររយ ដុល្លាអាមេរិកគត់) ឯខ្លួនយកទៅបញ្ចាំដល់ ២៥០ ដុល្លា ( ពីររយហាសិប ដុល្លាអាមេរិកគត់) ទើបវាខឹងនឹងខ្លួន ។ ក្នុងរឿងសម្លាប់មនុស្សនេះខ្លួនពុំដឹងអ្វីទេ ។ ចម្លើយនៅប៉ូលីសខ្លួនសុំបដិសេធចោល ពីព្រោះប៉ូលីសវាយដំបង្ខំខ្លួនអោយឆ្លើយ ខ្លួនក៏ចេះតែឆ្លើយតាមការបង្ខំរបស់គេទៅ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ថា : ការចោទប្រកាន់ខាងលើទុកជាត្រឹមត្រូវតាមច្បាប់ និង សុំអោយតុលាការផ្តន្ទាទោសយ៉ាងតឹងរ៉ឹងទៅតាមច្បាប់ ពីព្រោះចម្លើយជនជាប់ចោទបានឆ្លើយសារភាពនៅតុលាការ និង អយ្យការហើយ ។

-មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា : ជនជាប់ចោទទាំងបួននាក់ពិតជាអ្នកបានប្រព្រឹត្តអំពើមនុស្សឃាត កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ នៅមុខពេទ្យវិសាលសុខ ។ ហើយចម្លើយរបស់ជនជាប់ចោទបានសារភាព នៅចំពោះមុខចៅក្រមស៊ើបសួរ និងអយ្យការរួចហើយ ព្រមទាំងសាក្សីផង និង ប្រពន្ធរបស់ឈ្មោះ ម ម ផង ។ ខ្លួនសំណូមពរអោយតុលាការផ្តន្ទាទោសជនជាប់ចោទទាំងអស់ តាមបញ្ញត្តិមាត្រា ៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងសុំអោយតុលាការពិចារណាទៅលើសំណងរដ្ឋប្បវេណី ។

-មេធាវីរបស់ជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា : តាមចម្លើយរបស់កូនក្តីខ្ញុំ នៅនគរបាល និង តុលាការខុសគ្នា ។ នាពេលសវនាការនេះ ជនជាប់ចោទបានបដិសេធទាំងស្រុង ដោយចម្លើយទាំងនេះនគរបាលបានធ្វើទារុណកម្ម ហើយគំរាមឱ្យឆ្លើយ នៅពេលដែលបញ្ជូនមកតុលាការធ្វើអោយកូនក្តីរបស់ខ្ញុំមានការភ័យខ្លាចនៃអំពើទារុណកម្ម ។ ពុំមានភស្តុតាងណាបញ្ជាក់ និងដាក់បន្ទុកទៅលើកូនក្តីរបស់ខ្ញុំឡើយ ខ្ញុំសុំអោយតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំ ។

-ជនជាប់ចោទនិយាយសំដីចុងក្រោយថា សុំឱ្យតុលាការរកមុខរកឃាតករ និង រកយុត្តិធម៌ដល់ខ្ញុំផង ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យឈ្មោះ ឋ ស និងជនជាប់ចោទទាំងអស់រួមគ្នាសងជម្ងឺចិត្តសរុបចំនួន ៣២០ ០០០ ដុល្លា ( បីរយម្ភៃពាន់ ដុល្លាអាមេរិកគត់ ) និង សុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទាំងអស់ទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទទាំង ៤ នាក់

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និង ការប្តឹងសុំ

-ក្រោយពិបានស្តាប់ចម្លើយសាក្សីទាំងអស់

-ក្រោយពីបានស្តាប់អំណានចម្លើយជនល្មើសម្នាក់ៗ ក្នុងដំណាក់កាលស៊ើបអង្កេត

-ក្រោយពីបានស្តាប់អំណានលិខិតផ្សេងៗទៀត

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនល្មើសម្នាក់ៗ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

<u>តុលាការក្រុងភ្នំពេញ</u>

យល់ឃើញថា :

-ជនជាប់ចោទឈ្មោះ ឃ សរ ហៅ "ឋ ស", ឈ្មោះ រ ស ហៅ "ឋ", ឈ្មោះ ម មធ និង ឈ្មោះ ខ សច ហៅ "ណ" គឺសុទ្ធតែជានីតិជន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវតាមផ្លូវច្បាប់ ។

-ជនជាប់ចោទឈ្មោះ ឃ សរ ហៅ "ឋ ស" ពិតជាមានគំនុំជាមួយឈ្មោះ ម ម ក្នុងរឿងដែលឃ្លាំងបារីរបស់ខ្លួនឆេះនៅព្រំប្រទល់ប្រទេសវៀតណាមកន្លងមក ។

-តាមចម្លើយរបស់ជនជាប់ចោទទាំងអស់ដែលបានឆ្លើយនៅគ្រប់ដំណាក់កាលស៊ើបអង្កេត ហើយដែលអាចយកជាការបាននោះឃើញថា : អំពើឃាតកម្មលើឈ្មោះ ម ម កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ នោះ គឺផ្តើមឡើងដោយឈ្មោះ ឃ សរ ហៅ "ឋ ស" យ៉ាងពិតប្រាកដ ។

Scanned with CamScanner

-ទោះបីតែឈ្មោះ ឆ សរ ហៅ "ថ ស" និងឈ្មោះ រ ស ហៅ "ជ" រត់គេចខ្លួនបាត់ក៏ដោយ ក៏តាមចម្លើយរបស់ឈ្មោះ ម មធ ដែលឆ្លើយនៅដំណាក់កាលស៊ើបអង្កេត អាចយកជាការបាននោះ បញ្ជាក់ថា ឈ្មោះ ឆ សរ ហៅ "ថ ស" ពិតជាបានជួល ឈ្មោះ រ ស ហៅ "ជ" និងឈ្មោះ ម មធ អោយទៅសម្លាប់ឈ្មោះ ម ម ប្រាកដមែន ។

-តាមចម្លើយជនល្មើសឈ្មោះ ម មធ នៅដំណាក់កាលស៊ើបអង្កេតបញ្ជាក់ថា : ក្នុងពេលប្រព្រឹត្តបទល្មើស ឈ្មោះ ម មធ ជាអ្នកយកម៉ូតូត្រីសស្គាល់ឌុបឈ្មោះ រ ស ហៅ "ជ" ទៅបាញ់ឈ្មោះ ម ម នៅមុខមន្ទីរពេទ្យវិសាលសុខយ៉ាងពិតប្រាកដ ។

-ឈ្មោះ ម មធ ធ្លាប់ឆ្លើយសារភាពថា ខ្លួនធ្លាប់បានទទួលប្រាក់ចំនួន ៧០០ ដុល្លា (ប្រាំពីររយ ដុល្លាអាមេរិកគត់) ជាថ្លៃឈ្នួលសម្លាប់មនុស្សនេះដែរ ។

-ការចាប់ខ្លួនឈ្មោះ ជ សច ហៅ "ណឆ" គឺបណ្តាលមកពីសាក្សីឈ្មោះ អ ស ដែលបានរាយការណ៍ថា ឈ្មោះ ជ សច ធ្លាប់បានពឹងខ្លួនអោយជួយរកឃាតករសម្លាប់ឈ្មោះ ម ម ម្តងកាលពីខែ កញ្ញា ឆ្នាំ ១៩៩៧ ។

-តាមចម្លើយឈ្មោះ ជ សច ហៅ "ណឆ" នៅដំណាក់កាលស៊ើបអង្កេតបញ្ជាក់ថា : ធ្លាប់ឃើញឈ្មោះ រ ស ហៅ "ជ" និងឈ្មោះ ម មធ ទៅផ្ទះ ថ ស ហើយជួប ថ ស ដោយផ្ទាល់ ។

-ចម្លើយរបស់ឈ្មោះ ម មធ ដែលឆ្លើយថា ឈ្មោះ ជ សច បានជិះម៉ូតូតាមក្រោយ ក្នុងពេលប្រព្រឹត្តអំពើល្មើសនោះ សាម៉ីចម្លើយ និងឈ្មោះ ជ សច បានបដិសេធរួចហើយ ហើយក៏គ្មានភស្តុតាងណាបញ្ជាក់ថា ឈ្មោះ ជ សច ចូលរួមក្នុងអំពើឃាតកម្មនេះដែរ ។

-ឈ្មោះ ជ សច ហៅ "ណឆ" ជានគរបាលនៃក្រសួងមហាផ្ទៃ ដែលត្រូវមកធ្វើជាកងការពារអោយឈ្មោះ ថ ស ។ ដូច្នេះក្នុងករណីដែលឈ្មោះ ថ ស បានជួបជាមួយឃាតករដែលជា ឈ្មោះ រ ស ហៅ "ជ" ហើយនោះ គ្មានហេតុផលអ្វីដែលត្រូវអោយឈ្មោះ ជ សច ហៅ "ណឆ" ដឹងទៀតឡើយ ។

-អំពើឃាតកម្មលើឈ្មោះ ម ម នេះ មានទំនាក់ទំនងតែមនុស្សចំនួនបីនាក់ប៉ុណ្ណោះ គឺឈ្មោះ ថ ស ជាអ្នកផ្តើមគំនិត ឈ្មោះ រ ស ហៅ "ជ" ជាអ្នកបាញ់សម្លាប់ ហើយឈ្មោះ ម មធ ជាអ្នកជិះម៉ូតូឌុបឈ្មោះ រ ស ទៅបាញ់ ឈ្មោះ ម ម ។

-ឈ្មោះ ជ សច គ្រាន់តែជាអ្នកការពារអោយឈ្មោះ ថ ស ហើយពុំបានចូលទាក់ទងក្នុងរឿងឃាតកម្មលើឈ្មោះ ម ម កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ នោះឡើយ ។

-អំពើឃាតកម្មលើឈ្មោះ ម ម កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ កន្លងមកនេះ មានជាប់ទាក់ទងតែមនុស្សបីនាក់ប៉ុណ្ណោះ គឺឈ្មោះ ឆ សរ ហៅ "ថ ស" ឈ្មោះ រ ស ហៅ

"ជ" និងឈ្មោះ ម មន តែពុំឃើញ វិធីឈ្មោះ ជ សម ហៅ "ណត" មិនជាប់ទាក់ទង នឹងអំពើល្មើសកាលពីពេលនោះឡើយ ។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ រ ស ហៅ "ជ" និងឈ្មោះ ម មន ពីបទប្រព្រឹត្ត អំពើល្មើសឃាតកម្មដោយគិតទុកជាមុន ។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឡា សរ ហៅ "ថ ស" ពីបទសមគំនិតក្នុងអំពើ ឃាតកម្មដោយគិតទុកជាមុន ។

- ពុំមានពិរុទ្ធភាពដែលគួរអោយចោទប្រកាន់លើឈ្មោះ ជ សម ហៅ "ណត" ពីបទប្រព្រឹត្ត អំពើឃាតកម្ម កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ឡើយ ។

- ឈ្មោះនាង ស មន្សា ជាប្រពន្ធរបស់ឈ្មោះ ម ម បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទារសំណង និង ជម្ងឺចិត្តពីជនល្មើសមានលក្ខណៈសមស្របតាមច្បាប់ ដែលសំណូមពរនេះត្រឹមត្រូវ ដែលតុលាការគប្បីពិចារណា ។

- ជនរងគ្រោះមានកូនបន្សល់ទុក ៧ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីបានចំណាយធ្វើបុណ្យអស់ប្រាក់ ជាច្រើន ព្រមទាំងខាតបង់ប្រាក់ចំណូលជាច្រើនក្នុងមុខរបររបស់ប្តីខ្លួន ក្នុងពេលដែលប្តីខ្លួនបានស្លាប់ទៅ

- ជនជាប់ចោទជាអ្នកមានទ្រព្យសម្បត្តិច្រើន ហើយបានបង្កអន្តរាយដល់មុខរបរ និង ជោគវាសនាគ្រួសាររបស់ជនរងគ្រោះយ៉ាងធំធេង ។

- <u>វត្ថុតាងមាន</u> : ម៉ូតូម៉ាកគ្រឹសស្គាល់មួយគ្រឿង ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ម មន និង ជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីរឹបអូសទុកលក់យកប្រាក់ទូទាត់សំណង ។

- ចំពោះម៉ូតូម៉ាកសាន់យ៉ាងមួយគ្រឿង ជារបស់ឈ្មោះ ជ សម ហៅ "ណត" នោះពុំបាន ជាប់ទាក់ទងដល់អំពើល្មើសឡើយ គប្បីប្រគល់អោយឈ្មោះ ជ សម វិញ ។

## <u>ហេតុដូច្នេះ តុលាការក្រុងភ្នំពេញ</u>

## <u>វិនិច្ឆ័យសេចក្តី</u>

១- ផ្តន្ទាទោសលើឈ្មោះ :

-រ ស ហៅ "ជ" ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ។

-ម មន ដាក់ពន្ធនាគារកំណត់រយៈពេល ១០ ឆ្នាំ គិតពីថ្ងៃបានឃុំខ្លួនមក ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។

ពីបទធ្វើមនុស្សឃាតដោយគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ តាមបញ្ញត្តិមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ផ្តន្ទាទោសលើឈ្មោះ :

-ឡា សរ ហៅ "ថ ស" ដាក់ពន្ធនាគារកំណត់រយៈពេល ១៣ ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន

ពីបទសមគំនិត ប្រព្រឹត្តបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ តាមបញ្ញត្តិមាត្រា ៦៩ និង ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- អោយឈ្មោះ ៩ សច ហៅ "ណា" បានរួចផុតពីការចោទប្រកាន់ទោស ពីបទសមគំនិត ប្រព្រឹត្តអំពើមនុស្សឃាតដោយគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧។

៤- អោយឈ្មោះ ឃ សរ ហៅ "ថ ស" ឈ្មោះ រ ស ហៅ "៩" និងឈ្មោះ ម មធ រួមគ្នាសងសំណង និង ជម្ងឺចិត្តទៅអ្នកស្រី ស មឡ ជាប្រពន្ធរបស់ឈ្មោះ ម ម សរុបចំនួន ១០ម៉ឺន (ដប់ម៉ឺន) ដុល្លាអាមេរិក សំណូមពរលើសពីនេះត្រូវបដិសេធចោល ។

៥- ករណីជនណាមិនរួស ត្រូវដាក់គុកបង្ខំលើរូបរាងកាយ ដើម្បីទារប្រាក់ពិន័យតាមច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៦- <u>វត្ថុតាង</u> : ម៉ូតូសាន់យ៉ាន់មួយគ្រឿង ដែលជារបស់ឈ្មោះ ៩ សច ហៅ "ណា" ត្រូវអោយឈ្មោះ ៩ សច វិញ ។ រីឯម៉ូតូម៉ាកគ្រីសស្តាល់មួយគ្រឿង ជាមធ្យោបាយប្រព្រឹត្តបទល្មើស ត្រូវរឹបអូសទុកលក់ឡាយឡុង យកប្រាក់សងទៅដើមបណ្តឹងរដ្ឋប្បវេណី ។

៧- សាលក្រមនេះបានជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទឈ្មោះ ម មធ, ឈ្មោះ ៩ សច ហៅ "ណា" និងកំបាំងមុខជនជាប់ចោទឈ្មោះ ឃ សរ ហៅ "ថ ស", ឈ្មោះ រ ស ហៅ "៩" សំរេចបើកផ្លូវបណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ចៅក្រមជំនុំជំរះ

ហត្ថលេខា និង ត្រា

គ ភ

បានឃើញ

ចៅក្រមគុលាការ

ហត្ថលេខា

គ ភ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៨

ក្រឡាបញ្ជី

ហត្ថលេខា

ទ ចម



Scanned with CamScanner